the global voice of the legal profession



# យុត្តិធម៌ និងអំពើពុករលួយ

## បញ្ហាប្រឈមចំពោះឯករាជ្យភាពនៃប្រព័ន្ធតុលាការនៅកម្ពុជា

**ខែ កញ្ញា ឆ្នាំ ២០១៥**


របាយការណ៍របស់ International Bar Association's Human Rights Institute [វិទ្យាស្ថានសិទ្ធិមនុស្សនៃគណៈមេធាវីអន្តរជាតិ]

ឧបត្ថម្ភដោយមូលនិធិសប្បុរសធម៌នៃ International Bar Association's Human Rights Institute

របាយការណ៍នេះត្រូវបានចងក្រងឡើងស្របតាមគោលការណ៍ណែនាំលុនដ៍-ឡុនដុនដ៍ ឆ្នាំ២០០៩
(www.factfindingguidelines.org)

## សេចក្ដីសង្ខេប

នៅខែមេសា ឆ្នាំ ២០១៤ សង្គមស៊ីវិលបានដឹងពីការលេចធ្លាយសេចក្ដីព្រាងច្បាប់ថ្មីចំនួនបីស្ដីពីប្រព័ន្ធតុលាការនៅកម្ពុជា។ បញ្ញត្តិនៃច្បាប់ទាំងនោះបានធ្វើឲ្យមានការរិះគន់យ៉ាងខ្លាំងពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ហើយអ្នកផ្ដល់មតិបានបង្ហាញក្ដីបារម្ភថា សេចក្ដីព្រាងច្បាប់ទាំងនោះជាសញ្ញានៃការបង្កើតការគ្រប់គ្រងរបស់អំណាចនីតិប្រតិបត្តិលើប្រព័ន្ធតុលាការ ធ្វើឲ្យមានការអនុវត្តគ្មានក្រមសីលធម៌ក្រោមភាពស្របច្បាប់ និងត្រូវបានអនុម័តជាច្បាប់ដោយមិនមានការពិគ្រោះយោបល់ជាមួយសង្គមជារួម។ អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាជាច្រើនបានបោះពុម្ពបទរិះគន់ស្ដីពីកំហុសឆ្គងនៃសេចក្ដីព្រាងច្បាប់ទាំងនោះ និងស្នើឲ្យមានវិសោធនកម្មដោយសង្ឃឹមថារដ្ឋាភិបាលអាចពិចារណាពីចំណុចដែលស្នើឡើង មុនពេលអនុម័តច្បាប់ទាំងនោះ។

International Bar Association's Human Rights Institute (IBAHRI) បានបន្ថែមមតិយោបល់របស់ខ្លួនទៅនឹងបទរិះគន់ទាំងនេះកាលពីខែ កក្កដា នាអំឡុងឆ្នាំដដែល។ ក្នុងសន្និសីទសារព័ត៌មានបន្ទាន់មួយដែលធ្វើឡើងនៅទីក្រុងភ្នំពេញ ដោយមានវត្តមានអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីឯករាជ្យភាពនៃចៅក្រម និងមេធាវី លោកស្រី ហ្គាប្រ៊ីអេឡា ណោល [Gabriela Knaul] IBAHRI បានគូសបញ្ជាក់ថា សេចក្ដីសេចក្ដីព្រាងច្បាប់ទាំងនោះនឹងជះឥទ្ធិពលអវិជ្ជមានលើឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងអាចធ្វើឲ្យមានការផ្ទេរអំណាចយ៉ាងច្រើនពីតុលាការទៅស្ថាប័ននីតិប្រតិបត្តិ។ ទន្ទឹមនឹងនេះ IBAHRI បានជំរុញឲ្យអាជ្ញាធរពន្យារពេលដំណើរការនៃការដាក់ឲ្យសេចក្ដីព្រាងច្បាប់នោះក្លាយជាច្បាប់ និងជំរុញឲ្យមានការចូលរួមក្នុង "កិច្ចពិគ្រោះយោបល់ជាសាធារណៈស្ដីពីច្បាប់ទាំងនេះ"។

កិច្ចខិតខំប្រឹងប្រែងទាំងនេះបានក្លាយជាអសារបង់ ៖ នៅថ្ងៃបន្ទាប់ពីសន្និសីទសារព័ត៌មានរបស់ IBAHRI ព្រះមហាក្សត្របានឡាយព្រះហស្ថលេខាលើសេចក្ដីព្រាងច្បាប់ទាំងបី ឱ្យទៅជាច្បាប់ដែលបច្ចុប្បន្នបានគ្របដណ្ដប់ស្ទើរតែគ្រប់ផ្នែកទាំងអស់នៃក្របខ័ណ្ឌគតិយុត្តិនៅកម្ពុជា ដោយមិនមានការធ្វើវិសោធនកម្ម។ ជាការឆ្លើយតប គណៈប្រតិភូ IBAHRI បានធ្វើទស្សនកិច្ចមកកាន់ទីក្រុងភ្នំពេញកាលពីខែ មេសា ឆ្នាំ ២០១៥ ដើម្បីពិនិត្យស្ថានភាពប្រព័ន្ធតុលាការ និងវិជ្ជាជីវៈផ្នែកច្បាប់កម្ពុជាក្នុងបរិបទនៃច្បាប់ថ្មីទាំងបីដែលត្រូវបានអនុម័តនេះ។

របាយការណ៍នេះ ដែលជាលទ្ធផលនៃដំណើរទស្សនកិច្ច ការស្រាវជ្រាវ និងបទសម្ភាសជាបន្តបន្ទាប់ បានពិនិត្យជាដំបូងលើឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងសន្និដ្ឋានថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌កម្ពុជាបានទទួលតួនាទីដ៏មានអំណាចបំផុតទាំងផ្លូវច្បាប់ និងការអនុវត្តជាក់ស្តែងក្នុងប្រព័ន្ធយុត្តិធម៌ និងមានឆន្ទានុសិទ្ធិ និងឥទ្ធិពលលើផ្នែកស្ទើរតែទាំងអស់របស់ចៅក្រម។ បច្ចុប្បន្ន វិសាលភាពអំណាចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើប្រព័ន្ធតុលាការ ដូចជា ឥទ្ធិពលផ្លូវការយ៉ាងច្រើនលើផ្នែកថវិកា ធនធាន ការបណ្តុះបណ្តាល ការតែងតាំង ការដំឡើងតំណែង រយៈពេលកាន់តំណែង និងការដកចេញ នៅក្នុងប្រព័ន្ធតុលាការ ត្រូវបានចែងក្នុងច្បាប់ថ្មីទាំងបី ដែលគ្មានសង្គតិភាពជាមួយបទដ្ឋានអន្តរជាតិឡើយ។

ក្រៅពីនេះ របាយការណ៍នេះបានពិចារណាពីបញ្ហាប្រឈមផ្សេងទៀតក្នុងប្រព័ន្ធតុលាការកម្ពុជា ជាពិសេស ការស៊ីសំណូក និងអំពើពុករលួយ។ ឥទ្ធិពលនៃអំពើពុករលួយ ទាំងផ្នែកនយោបាយ និងហិរញ្ញវត្ថុ ហាក់បានលេចឡើងដោយឆន្ទៈលើសកម្មភាពទាំងអស់របស់តុលាការ។ ចៅក្រមដែលកំពុងបណ្តុះបណ្តាល ត្រូវបានស្នើឲ្យបង់ប្រាក់សំណូកដើម្បីអាចចូលរួមក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយចៅក្រមដែលជាសមាជិករបស់គណបក្សប្រជាជនកម្ពុជា មានលទ្ធភាពច្រើនក្នុងទទួលបានការតែងតាំង និងការដំឡើងតំណែង។ គេសុទ្ធតែបានដឹងថា សេចក្តីសម្រេចរបស់តុលាការត្រូវបានកំណត់ដោយសម្ពាធហិរញ្ញវត្ថុ និងនយោបាយលើចៅក្រម ៖ ករណីដែលអាជ្ញាធរទទួលបានផលប្រយោជន៍ ត្រូវបានដោះស្រាយដោយស៊ីសង្វាក់គ្នាទៅតាមការអនុគ្រោះរបស់ពួកគេ ហើយក្នុងករណីផ្សេងទៀត ភាគីដែលអាចផ្តល់សំណូកកាន់តែច្រើនដល់ចៅក្រម ឬក្រឡាបញ្ជី នឹងឈ្នះរឿងក្តីដោយមិនគិតពីអង្គសេចក្តី។

ក្រៅពីអំពើពុករលួយ ប្រព័ន្ធតុលាការក៏ប្រឈមនឹងបញ្ហាខ្វះតំណាងស្ត្រីក្នុងសមាសភាពចៅក្រម ហើយក្រឡាបញ្ជី និងអាជ្ញាសាលាបានដណ្តើមតួនាទីរបស់ចៅក្រមដោយធ្វើជាប្រធានកាត់ក្តីដោយប្រសិទ្ធភាពលើរឿងក្តីរបស់ពួកគេ ដែលពេលខ្លះចៅក្រមតែងតាំងបានដឹង និងពេលខ្លះមិនបានដឹងពីករណីនេះ។ លទ្ធផលនៃសកម្មភាពទាំងនេះគឺ តុលាការត្រូវបានគេមើលឃើញថាជាការពង្រីកអំណាចរបស់រដ្ឋាភិបាលនៅកម្ពុជា។ ប្រជាជនសាមញ្ញមានការភ័យខ្លាច និងស្អប់ខ្ពើមមិនចង់ពាក់ព័ន្ធជាមួយតុលាការឡើយ ក្នុងករណីដែលពួកគេអាចធ្វើបាន។

ក្នុងការពិនិត្យតួនាទីនៃវិជ្ជាជីវៈផ្នែកច្បាប់នៅកម្ពុជា ដែលជាផ្នែកដ៏សំខាន់នៃក្របខ័ណ្ឌដែលគាំទ្រប្រព័ន្ធតុលាការ IBAHRI បានរកឃើញបញ្ហាធ្ងន់ធ្ងរស្រដៀងគ្នាមួយចំនួន។ ជាពិសេស របាយ

ការណ៍នេះរកឃើញថា គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា (BAKC) មានភាពពាក់ព័ន្ធផ្នែកនយោបាយខ្លាំងពេកមិនអាចបំពេញមុខងាររបស់ខ្លួនបានសមស្របក្នុងការធ្វើជាតំណាង និងការគស្ស៊ូមតិគាំទ្រមេធាវី និងវិជ្ជាជីវៈផ្នែកច្បាប់ឡើយ។ មានការចោទប្រកាន់ដ៏គួរឲ្យទុកចិត្តថា គណៈមេធាវីទទួលសំណូកពីមេធាវីដែលចូលរួមក្នុងការបណ្តុះបណ្តាល រិតត្បិតលើចំនួនមេធាវីដែលចូលក្នុងវិជ្ជាជីវៈ អនុញ្ញាតឲ្យសមាជិកគ្មានគុណវុឌ្ឍិរបស់គណបក្សប្រជាជនកម្ពុជាចូលរួមក្នុងសមាសភាពរបស់ខ្លួន និងត្រូវបានគ្រប់គ្រងដោយគណបក្សនេះ និងរដ្ឋាភិបាល។ ការចោទប្រកាន់ចុងក្រោយនេះត្រូវបានបញ្ជាក់ដោយការដកហូតការគាំទ្ររបស់គណៈមេធាវីពីមេធាវី ដែលពូកែធ្វើជាតំណាងឲ្យកូនក្តីដែលតតាំងរឿងក្តីប្រឆាំងនឹងផលប្រយោជន៍របស់រដ្ឋ ហើយមេធាវីទាំងនោះត្រូវបានប្រឈមនឹងការចោទប្រកាន់មូលបង្កាច់ពីបទព្រហ្មទណ្ឌ។

អំពើពុករលួយក្នុងប្រព័ន្ធតុលាការ និងកង្វះការគាំទ្រពីរដ្ឋាភិបាលលើវិជ្ជាជីវៈផ្នែកច្បាប់បានបង្កការរាំងស្ទះខ្លាំងលើសមត្ថភាពរបស់សាធារណជនក្នុងការទទួលបានការណែនាំ និងតំណាងផ្លូវច្បាប់។ នៅកម្ពុជា ថវិកាជំនួយផ្នែកច្បាប់មិនគ្រប់គ្រាន់សម្រាប់ការផ្តល់ជំនួយផ្លូវច្បាប់សមស្របដល់អ្នកដែលមានតម្រូវការឡើយ ដែលពួកគេភាគច្រើនតតាំងរឿងក្តីក្នុងតុលាការដោយមិនមានតំណាង។ ក្នុងករណីដែលមានមេធាវីតំណាង ជាញឹកញាប់ ពួកគេទទួលបានពេលវេលាតិចតួចក្នុងការពិគ្រោះយោបល់ជាមួយកូនក្តី និងត្រូវបានស្នើឲ្យបង់ប្រាក់សំណូកដើម្បីអាចមើលឯកសាររបស់តុលាការបាន។ មេធាវីជាច្រើន (ទោះបីជាមិនមែនទាំងអស់ក្តី) បានពាក់ព័ន្ធក្នុងការផ្តល់សំណូក និងយល់ថា នេះជាមធ្យោបាយតែមួយគត់ក្នុងការឈ្នះរឿងក្តី ដែលនេះជាការគូសបញ្ជាក់ពីវិសាលភាពដ៏ធំធេងនៃអំពើពុករលួយដែលមិនអាចបញ្ចៀសបាននៅក្នុងប្រព័ន្ធតុលាការកម្ពុជា។ ជាលទ្ធផលនៃសកម្មភាពទាំងនេះ និងការណ៍ដែលប្រជាជនជាច្រើនមិនមានការយល់ដឹងពីកិច្ចការរបស់មេធាវី ទំនុកចិត្តរបស់សាធារណជនលើវិជ្ជាជីវៈផ្នែកច្បាប់មានកម្រិតទាបបំផុត។

ចំណុចចុងក្រោយបំផុតនោះគឺ របាយការណ៍នេះពិចារណាពីស្ថាប័ន និងភាគីពាក់ព័ន្ធផ្សេងទៀត (ជំពូកទី ៥) ដែលដំបូងបង្អស់គឺប្រជាជនកម្ពុជាដែលត្រូវបានបំបិទសិទ្ធិដីធ្លី។ ការបណ្តេញសហគមន៍បឹងកក់ (នៅភាគខាងជើងទីក្រុងភ្នំពេញ) ពីដីធ្លី បន្ទាប់ពីរដ្ឋាភិបាលបានលក់ដីនោះទៅឲ្យក្រុមហ៊ុនឯកជនមួយ គឺជាស្ថានភាពទូទៅមួយរបស់ប្រជាជនរាប់ពាន់នាក់នៅកម្ពុជា។ ការស្វាក់ស្វើរក្នុងការងាកទៅរកជំនួយពីតុលាការដើម្បីទាមទារសិទ្ធិរបស់ខ្លួន ឆ្លុះបញ្ចាំងឱ្យឃើញពីមន្ទិល

សង្ស័យរបស់ប្រជាជនជាច្រើន និងការបាត់បង់ចំណាប់អារម្មណ៍របស់ពួកគេលើប្រព័ន្ធតុលាការកម្ពុជា។

ស្ថាប័ន និងភាគីពាក់ព័ន្ធពីរទៀតដែលត្រូវបានពិចារណាក្នុងរបាយការណ៍នេះ និងការស្វែងរកការពិតរបស់ IBAHRI គឺគណបក្សសង្គ្រោះជាតិ ដែលជាគណបក្សប្រឆាំងដ៏ធំបំផុតនៅកម្ពុជា និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អវតក)។ អ្វីដែលគួរឲ្យកោតសរសើរនោះគឺគណបក្សសង្គ្រោះជាតិ បានបញ្ចូលកំណែទម្រង់ប្រព័ន្ធតុលាការទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន។ ទោះជាយ៉ាងណា គណបក្សនេះបានសមគំនិតក្នុងកិច្ចព្រមព្រៀងដែលធានាអំណាចរបស់ស្ថាប័ននីតិប្រតិបត្តិលើតុលាការ។ ទន្ទឹមនឹងនេះ ខណៈដែលពេលខ្លះ អ.វ.ត.ក ត្រូវបានកាត់ផ្តាច់ចេញពីបញ្ហាដែលកើតមានច្រើនលើផ្នែកផ្សេងទៀតរបស់ប្រព័ន្ធតុលាការ តុលាការនេះនៅតែប្រឈមនឹងសម្ពាធនយោបាយពីរដ្ឋាភិបាលទីក្រុងភ្នំពេញ និងម្ចាស់ជំនួយអន្តរជាតិ ដោយមានការចោទប្រកាន់ថាម្ចាស់ជំនួយអន្តរជាតិមួយចំនួននឹងដកប្រាក់ជំនួយប្រសិនបើអវតកចេញសាលក្រម "មិនត្រឹមត្រូវ"។

ប៉ុន្តែស្ថានភាពសម្រាប់ប្រទេសកម្ពុជាមិនទាន់ទាល់ច្រកនោះទេ។ ទោះបីជាមានបញ្ហាប្រឈមជាច្រើនក៏ដោយ ក៏នៅតែមានក្តីសង្ឃឹមជាច្រើនសម្រាប់ប្រព័ន្ធតុលាការកម្ពុជា និងវិជ្ជាជីវៈផ្នែកច្បាប់ ប្រសិនបើច្បាប់ថ្មីទាំងបីត្រូវបានធ្វើវិសោធនកម្មសមស្រប ហើយគោលនយោបាយនានាត្រូវបានអនុវត្តដោយភាគីពាក់ព័ន្ធ ដើម្បីចាប់ផ្តើមផ្លាស់ប្តូរការខាតបង់ដែលបានកើតមានកន្លងមក។ ក្នុងជំពូកទី ៦ IBAHRI បានផ្តល់អនុសាសន៍ដល់រដ្ឋាភិបាលកម្ពុជា រដ្ឋសភា និងព្រឹទ្ធសភា ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា គណបក្សសង្គ្រោះជាតិ សហគមន៍អង្គការមិនមែនរដ្ឋាភិបាល សហគមន៍អន្តរជាតិ International Bar Association (IBA) [គណៈមេធាវីអន្តរជាតិ] និងសហគមន៍ជំនួញអន្តរជាតិ ដើម្បីចាប់ផ្តើមដំណើរការដោះស្រាយបញ្ហាដែលលើកឡើងក្នុងរបាយការណ៍នេះ និងពង្រឹកការការពារឯករាជ្យភាពនៃប្រព័ន្ធតុលាការ។ មានហេតុផលដែលបញ្ជាក់ថា នៅពេលមានការគាំទ្រត្រឹមត្រូវ ចៅក្រម និងមេធាវីកម្ពុជាអាចចាប់ផ្តើមដើរតួនាទីវិជ្ជមានក្នុងការការពារសិទ្ធិបុគ្គល និងផ្តល់យុត្តិធម៌ដល់ប្រជាជនសាមញ្ញ។

# ជំពូកទី ៦ ៖ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ៦.១ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍សម្រាប់រដ្ឋាភិបាលកម្ពុជា (រួមទាំងក្រសួងយុត្តិធម៌)

ខណៈដែលរដ្ឋាភិបាលកម្ពុជា ប្ដេជ្ញាធ្វើកំណែទម្រង់ប្រព័ន្ធតុលាការក្នុងយុទ្ធសាស្ត្រចតុកោណ ច្បាស់ណាស់ថាត្រូវមានមានការវាយតម្លៃឡើងវិញលើជំនួយហិរញ្ញវត្ថុ ដែលខ្លួនផ្ដល់ដល់ប្រព័ន្ធតុលាការ និងវិធីសាស្ត្រដែលសមាជិកមួយចំនួនរបស់រដ្ឋាភិបាលអនុវត្តក្នុងទំនាក់ទំនងរវាងពួកគេ និង ប្រព័ន្ធតុលាការ។ ការធានាដោយរដ្ឋធម្មនុញ្ញ និងផ្លូវច្បាប់លើឯករាជ្យភាពភាពមិនស៊ីសង្វាក់គ្នានឹងការធានាជាក់ស្ដែងគ្រប់គ្រាន់នៃឯករាជ្យភាពភាពឡើយ។ ក្នុងការអនុវត្ត ប្រព័ន្ធតុលាការ ដែលនៅឆ្ងាយពីស្វ័យអភិបាលកិច្ច នៅតែមិនទទួលបានមូលនិធិគ្រប់គ្រាន់ និងប្រឈមនឹងឥទ្ធិពលនយោបាយលើមុខងាររបស់ខ្លួន ដែលរាំងស្ទះខ្លាំងដល់សមត្ថភាពអភិវឌ្ឍរបស់ខ្លួន។

អាស្រ័យហេតុនេះ IBAHRI សូមផ្ដល់អនុសាសន៍ឲ្យរដ្ឋាភិបាលកម្ពុជា (រួមទាំងក្រសួងយុត្តិធម៌) ៖

- ចាត់វិធានការបន្ទាន់បញ្ឈប់ការដាក់សម្ពាធនយោបាយលើប្រព័ន្ធតុលាការ ដោយសមាជិករដ្ឋាភិបាល
- ប្ដេជ្ញាធានា និងការពារការបែងចែកអំណាចនៅកម្ពុជា និងគោរពឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងគណៈមេធាវី។ ខណៈដែលច្បាប់បានបង្កើតទំនាក់ទំនងរវាងតុលាការ និងក្រសួងយុត្តិធម៌ ក្រសួងនេះមិនគួរពាក់ព័ន្ធលើសពីបញ្ហារដ្ឋបាលដែលមិនរាំងស្ទះឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងគណៈមេធាវី
- ធានាថា ព័ត៌មានមូលដ្ឋានស្ដីពីប្រព័ន្ធច្បាប់កម្ពុជា និងសិទ្ធិ និងកាតព្វកិច្ចប្រជាជនត្រូវបានបង្រៀនក្នុងកម្មវិធិសិក្សា។ ពលរដ្ឋគួរយល់ដឹងពីសិទ្ធិផ្លូវច្បាប់ និងវិធីដែលច្បាប់ទាំងនោះអាចការពារពួកគេបាន
- ចាប់ផ្ដើមងាកចេញពីការពឹងផ្អែកលើជំនួយបរទេសដើម្បីជួយដល់ប្រព័ន្ធច្បាប់ និងប្ដេជ្ញាបែងចែកថវិកាជាតិគ្រប់គ្រាន់ដើម្បីជួយកែលម្អប្រព័ន្ធច្បាប់ និងរួមបញ្ចូលនីតិរដ្ឋទៅក្នុងសង្គមកម្ពុជា
- បង្កើនថវិកាសម្រាប់កម្មវិធីជំនួយផ្នែកច្បាប់ដែលធ្វើឡើងតាមរយៈគណៈមេធាវី និងធ្វើសវនកម្មជាប្រចាំដើម្បីធានាថា កម្មវិធីជំនួយផ្នែកច្បាប់មានប្រសិទ្ធភាពក្នុងការធានាថា រាល់បុគ្គលដែលចោទប្រកាន់ពីបទឧក្រិដ្ឋនៅកម្ពុជាមានលទ្ធភាពទទួលបានការប្រឹក្សា និងតំណាងផ្នែកច្បាប់

- បង្កើនថវិកាទូទៅដល់ប្រព័ន្ធតុលាការ។ ចៅក្រម និងមេធាវីគួរមានថវិកាគ្រប់គ្រាន់ដើម្បីទទួលបានប្រាក់បៀវត្សរ៍ ទីកន្លែងសមស្រប និងបុគ្គលិកគ្រប់គ្រាន់ដើម្បីលើកកម្ពស់ និងជំរុញសិទ្ធិផ្លូវច្បាប់។ គួរផ្តល់ថវិកាសមស្របសម្រាប់ការពង្រីកចំនួនតុលាការ ចៅក្រម និងមេធាវី សំដៅផ្តល់លទ្ធភាពទទួលបានយុត្តិធម៌កាន់តែច្រើនដល់ប្រជានជន និងជាពិសេសអ្នកដែលរស់នៅក្រៅក្រុងភ្នំពេញ
- បន្តលើកកម្ពស់សិទ្ធិមនុស្ស និងការបណ្តុះបណ្តាលផ្នែកច្បាប់ទូទៅដល់សិស្សនិស្សិតច្បាប់ តាមរយៈវគ្គវិញ្ញាបនបត្រមុនពេលបញ្ចប់ការសិក្សា។ ពិចារណាលើការតម្រូវឲ្យសិស្សនិស្សិតច្បាប់ទាំងអស់សិក្សាវគ្គយ៉ាងតិចមួយស្តីពីច្បាប់សិទ្ធិមនុស្ស
- ពិចារណាបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាប្រទេសសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) សម្រាប់ការផ្តល់ការបណ្តុះបណ្តាលផ្នែកច្បាប់ និងការកសាងសមត្ថភាពដល់មេធាវីទាំងឡាយ ដោយផ្អែកលើការកែលម្អវិស័យនេះក្នុងរយៈពេលពីរបីឆ្នាំកន្លងមក
- ធានាថាស្ត្រី មានឱកាសស្មើគ្នាក្នុងវឌ្ឍនភាពអាជីពដូចបុរស។ ឥរិយាបថ និងសកម្មភាពរបស់មន្ត្រីរដ្ឋាភិបាលដែលផ្អែកលើការរើសអើង គួរត្រូវបានដោះស្រាយតាមរយៈការបណ្តុះបណ្តាលចំណាត់ការវិន័យ និងការវិនិច្ឆ័យឧក្រិដ្ឋកម្ម ក្នុងករណីសមស្រប និង
- ផ្តល់ជំនួយដល់សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងភាគីផ្សេងទៀតដើម្បីពិនិត្យ និងផ្សព្វផ្សាយពីកំហុសឆ្គងនានាជាសាធារណៈរបស់ស្ថាប័នរដ្ឋទាំងអស់ រួមទាំងអង្គនីតិប្រតិបត្តិ និងប្រព័ន្ធតុលាការ។ មិនគួរមានការរារាំងផ្នែករដ្ឋបាល ឬឧបសគ្គផ្សេងទៀតលើសកម្មភាពរបស់សង្គមស៊ីវិលឡើយ។

## ៦.២ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់រដ្ឋាភិបាលកម្ពុជា រដ្ឋសភា ព្រឹទ្ធសភា និងព្រះមហាក្សត្រ

គណៈប្រតិភូ IBAHRI ស្វាគមន៍ការជំរុញឲ្យមានការបង្កើតក្របខ័ណ្ឌគតិយុត្តិកាន់តែរឹងមាំដើម្បីគ្រប់គ្រងសកម្មភាព និងចំណាត់ការនានារបស់ប្រព័ន្ធតុលាការនៅកម្ពុជា។ យ៉ាងនេះក្តី គណៈប្រតិភូបានកំណត់ក្តីបារម្ភសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងបញ្ញត្តិនៃច្បាប់ថ្មីទាំងបី ដែលប្រសិនបើមិនមានការដោះស្រាយ នឹងអាចធ្វើឲ្យមានការអនុវត្តមិនល្អដែលរាំងស្ទះគោលការណ៍គ្រឹះនៃការបែងចែកអំណាច និងឯករាជ្យភាពនៃប្រព័ន្ធតុលាការ។

អំណាចដែលផ្តល់ដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើប្រព័ន្ធតុលាការកម្ពុជា គឺមិនសមស្របនឹងគោលការណ៍ដែលឥទ្ធិពលនៃអំណាចនីតិប្រតិបត្តិលើកិច្ចការតុលាការ គួរតែមានកម្រិតនោះទេ។

IBAHRI ស្នើឡើងដោយបន្ទាន់ ថា រដ្ឋាភិបាលកម្ពុជា រដ្ឋសភា ព្រឹទ្ធសភា និងព្រះមហាក្សត្រ គួរធ្វើវិសោធនកម្មច្បាប់ថ្មីទាំងបីដើម្បីធានានូវការអនុលោមតាមគោលការណ៍ឯករាជ្យភាពនៃអំណាចតុលាការ។ ជាពិសេស ៖

ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

- ធ្វើវិសោធនកម្មមាត្រា ៤ ដើម្បីលុបចោលតួនាទីរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងសមាជិករបស់រដ្ឋសភា និងព្រឹទ្ធសភាលើឧត្តមក្រុប្រឹក្សានៃអង្គចៅក្រម។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរមានសមាសភាពដែលមិនមានទំនាក់ទំនងជាមួយអំណាចនីតិប្រតិបត្តិ ឬនីតិបញ្ញត្តិ
- ធ្វើវិសោធនកម្មមាត្រា ៨ និងមាត្រា ១៥ ដើម្បីបង្កើតស្ថាប័នឯករាជ្យភាពដោយមិនមានទំនាក់ទំនងជាមួយអំណាចនីតិប្រតិបត្តិ ឬអំណាចនីតិបញ្ញត្តិ ដែលគ្រប់គ្រងថវិកា និងរដ្ឋបាលនៃកិច្ចការតុលាការ។ ទោះបីជាថវិកាតុលាការត្រូវផ្តល់ដោយរដ្ឋ ប៉ុន្តែនៅពេលដែលថវិកានោះត្រូវបានផ្តល់ឱ្យស្ថាប័នពាក់ព័ន្ធ វាគួរត្រូវបានចាត់ចែង និងគ្រប់គ្រងផ្តាច់មុខដោយស្ថាប័នឯករាជ្យភាពពីអំណាចនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ
- ធ្វើវិសោធនកម្មមាត្រា ២៣ និង ២៥ ដើម្បីលុបចោលតួនាទីរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក្នុងដំណើរការវិន័យ ទាំងក្នុងនាមជាអ្នកពិនិត្យបណ្តឹង និងជាសមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និង
- ធ្វើវិសោធនកម្មមាត្រា ៦៧ ដើម្បីលុបចោលអំណាចរបស់រដ្ឋមន្ត្រីក្នុងការផ្តល់អនុសាសន៍ចំពោះការចូលនិវត្តន៍របស់ចៅក្រមលើគ្រប់ហេតុផល។ អនុសាសន៍ទាំងនោះគួរចេញពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដែលមិនលម្អៀង និងឯករាជ្យភាព។

ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ៖

- ធ្វើវិសោធនកម្មមាត្រា ៣៣ ដើម្បីលុបចោលតួនាទីរបស់រដ្ឋមន្ត្រីលើគណៈកម្មាធិការដំឡើងតំណែងតាមកម្រិត និងលំដាប់ថ្នាក់ (CPGR) និងធានាថា គណៈកម្មាធិការនេះជាស្ថាប័នបរានុម័តដែលមានឯករាជ្យភាពពីឥទ្ធិពលខាងក្រៅ។

ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ

- ធ្វើវិសោធនកម្មមាត្រា ១១ ដើម្បីលុបចោលតួនាទីរបស់រដ្ឋមន្ត្រីក្នុងការគ្រប់គ្រងតុលាការ និងសាលាជម្រះក្តី

- ធ្វើវិសោធនកម្មមាត្រា ៧៩ ដើម្បីបែងចែកថវិការបស់តុលាការពីថវិការបស់ក្រសួងយុត្តិធម៌។ តុលាការគួរទទួលបានថវិកាផ្ទាល់ខ្លួនដោយឡែកពីថវិការដ្ឋ និងមិនគួរពឹងផ្អែកលើថវិការបស់ក្រសួងនេះឡើយ។

តាមរយៈការផ្អាកការធ្វើកំណែទម្រង់លើច្បាប់ថ្មីទាំងបី ច្បាប់ទាំងនេះមិនគួរយកមកអនុវត្តក្នុងករណីដែលធ្វើឲ្យមានការរាំងស្ទះឯករាជ្យភាពនៃអំណាចតុលាការដែលធ្វើឲ្យមានអយុត្តិធម៌ឡើយ។

## ៦.៣ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

ក្នុងនាមជាស្ថាប័នដែលទទួលខុសត្រូវចុងក្រោយលើការគ្រប់គ្រងប្រព័ន្ធតុលាការ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវដើរតួនាទីសំខាន់ក្នុងការធានាឯករាជ្យភាព វិជ្ជាជីវៈ និងគណនេយ្យភាពនៃប្រព័ន្ធតុលាការ។ គណៈប្រតិភូ IBAHRI បានកំណត់បញ្ហាកង្វល់សំខាន់ៗលើផ្នែកពីរពាក់ព័ន្ធនឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ទី១ ឥទ្ធិពលរបស់ស្ថាប័ននីតិប្រតិបត្តិលើឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ភាគច្រើនតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានលក្ខណៈជ្រុលហួសហេតុ និងរាំងស្ទះដល់ឯករាជ្យភាពរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ទី២ IBAHRI បានកំណត់បញ្ហាមួយចំនួនលើផ្នែកសំខាន់ៗដែលឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទទួលខុសត្រូវ ដូចជា ការជ្រើសរើស ការបណ្តុះបណ្តាល ការដាក់វិន័យ និងវិជ្ជាជីវៈរបស់ចៅក្រម។

ក្នុងនាមជាស្ថាប័នដែលតុលាការត្រូវអនុវត្តស្វ័យអភិបាលកិច្ច បច្ចុប្បន្ន ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមិនបានធ្វើជាតំណាងគ្រប់គ្រាន់ដើម្បីធានាឯករាជ្យភាពនៃប្រព័ន្ធតុលាការឡើយ ពិសេសនៅពេលដែលត្រូវប្រឆាំងនឹងសម្ពាធពីអង្គនីតិប្រតិបត្តិ។ គណៈប្រតិភូព្រួយបារម្ភដោយសាររបាយការណ៍រៀបរាប់ជាច្រើនស្តីពីឥទ្ធិពលនយោបាយនៃវិធានការវិន័យ ការជ្រើសរើស និងការដំឡើងតំណែងចៅក្រមទៅតាមទំនាក់ទំនងនយោបាយ និងការស៊ីសំណូកដែលកើតមានជាទូទៅក្នុងតុលាការកម្ពុជាចាប់ពីដើមដំបូងនៃអាជីពរបស់ចៅក្រម។

អាស្រ័យហេតុនេះ IBAHRI សូមផ្តល់អនុសាសន៍ឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ៖

- ចាត់វិធានការសកម្មក្នុងការដោះស្រាយអំពើពុករលួយលើប្រព័ន្ធតុលាការនៅកម្ពុជា។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមគួរអនុវត្តប្រព័ន្ធជាប្រចាំនៃការត្រួតពិនិត្យលើតុលាការ និងមន្ត្រីតុលាការដើម្បីធានាបាននូវការលុបបំបាត់ការស៊ីសំណូក និងការជ្រៀតជ្រែកនយោបាយ

- អនុវត្តប្រព័ន្ធការពារនៅពេលដែលមានពាក្យបណ្តឹងលើចៅក្រម និងព្រះរាជអាជ្ញាដើម្បីបញ្ឈប់ការ "សងសឹក" របស់ចៅក្រមលើបណ្តឹងដោយមេធាវីក្នុងតុលាការ
- ធានាថា ក្តារប្រកាសព័ត៌មានដែលគេអាចមើលឃើញជាសាធារណៈ មានកំណត់ប្រាក់កម្រៃរបស់មន្ត្រីតុលាការ និងត្រូវបានផ្សព្វផ្សាយនៅគ្រប់តុលាការទាំងអស់ ហើយការផ្តល់ប្រាក់កម្រៃត្រូវមានឯកសារពេញលេញ និងធ្វើសវនកម្មជាប្រចាំ
- ធានាថា ក្នុងករណីដែលត្រូវចាត់វិធានការវិន័យលើចៅក្រម និងព្រះរាជអាជ្ញា វិធានការទាំងនេះត្រូវមានតម្លាភាព និងអនុលោមតាមបទដ្ឋានអន្តរជាតិ
- បោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំសម្រាប់តុលាការគ្រប់ជាន់ថ្នាក់ ដែលផ្តល់ព័ត៌មានដល់សាធារណៈជន អំពីចំនួនករណី ចំនួនចៅក្រម ប្រាក់បៀវត្សរ៍របស់មន្ត្រីតុលាការ និងការរៀបចំឯកសារអំពីចំនួន និងលក្ខណៈនៃបណ្តឹង ក៏ដូចជាចំណាត់ការរបស់អាជ្ញាធរចំពោះបណ្តឹងទាំងនោះ
- អនុវត្តប្រព័ន្ធមានអាណត្តិដែលបន្តការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់ចៅក្រម និងព្រះរាជអាជ្ញាដែលផ្តល់ការអប់រំសមស្របស្តីពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងក្រមប្រតិបត្តិ និងសីលធម៌
- ចូលរួមចំណែកដល់បរិយាកាសដែលចៅក្រម និងព្រះរាជអាជ្ញាស្រីត្រូវបានផ្តល់សិទ្ធិអំណាចដើម្បីបន្តអាជីពរបស់ខ្លួនដូចគ្នានឹងបុរស
- ចាត់វិធានការបង្កើតតុលាការឯកទេស ដូចជា តុលាការអនីតិជន តុលាការគ្រួសារ និងនិងតុលាការផ្សេងទៀត ឲ្យបានឆាប់បំផុត
- ប្រើប្រាស់បច្ចេកវិជ្ជាកុំព្យូទ័រ និងប្រព័ន្ធនានាក្នុងប្រព័ន្ធតុលាការ ដើម្បីមន្ត្រីតុលាការ មេធាវីនិងសាធារណៈជនអាចចូលមើលកំណត់ត្រាតុលាការ សំណុំរឿង ការវិនិច្ឆ័យ និងឯកសារផ្សេងទៀតបានដោយងាយ ក្នុងករណីសមស្រប និង
- អនុញ្ញាតឲ្យចៅក្រមផ្តល់មតិជាសាធារណៈ ដោយមិនមានការយល់ព្រមជាមុនណាមួយពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬស្ថាប័នផ្សេងទៀត ដរាបណាចៅក្រមអនុលោមតាមក្របខ័ណ្ឌដែលបង្កើតឡើងដោយក្រមប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួន។

## ៦.៤ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

គណៈមេធាវី ដែលជាស្ថាប័នតំណាងឲ្យវិជ្ជាជីវៈផ្នែកច្បាប់នៅកម្ពុជា គួរបំពេញតួនាទីការពារសមាជិករបស់ខ្លួន ជាពិសេសប្រឆាំងនឹងចំណាត់ការ និងការលុបចោលណាមួយ ដោយអំណាចនីតិប្រតិបត្តិដែលគំរាមកំហែងដល់សុចរិតភាព ឯករាជ្យភាព និងភាពរស់រាននៃវិជ្ជាជីវៈផ្នែកច្បាប់។

គណៈប្រតិភូ IBAHRI ព្រួយបារម្ភជាខ្លាំងចំពោះការចោទប្រកាន់នានាដែលបញ្ជាក់ថា គណៈមេធាវីមិនបានគាំទ្រវិជ្ជាជីវៈផ្នែកច្បាប់នៅកម្ពុជា និងតែងតែបង្កគ្រោះថ្នាក់ដល់វិជ្ជាជីវៈនេះទៀតផង។ ជាក់ស្តែង គណៈមេធាវីមិនឯករាជ្យភាពពីរដ្ឋាភិបាលកម្ពុជា និងមិនអាចបំពេញតួនាទីជាស្ថាប័ននិយ័តកម្មប្រកបដោយអត្ថន័យ ដែលអាចការពារផលប្រយោជន៍របស់សមាជិក និងសាធារណៈជន។ កង្វះឯករាជ្យភាពនេះលេចឡើងយ៉ាងច្បាស់នៅក្នុងចំណុចជាច្រើននៃកំណត់ត្រាតាមដានរបស់គណៈមេធាវីរួមមាន របៀបនៃការបោះឆ្នោតពីមុន និងភាពស្ទាក់ស្ទើររបស់គណៈមេធាវីក្នុងការរិះគន់សកម្មភាពរបស់រដ្ឋាភិបាល ដូចជាពាក់ព័ន្ធនឹងច្បាប់ថ្មីទាំងបីជាដើម បើទោះជាសមាជិករបស់ខ្លួនបានធ្វើការរិះគន់អំពីបញ្ហាទាំងនោះក៏ដោយក្តី។

ក្រៅពីនេះ ភាពផ្តាច់មុខរបស់គណៈមេធាវីលើការបណ្តុះបណ្តាលផ្លូវច្បាប់ និងគោលនយោបាយរិតត្បិតរបស់ខ្លួនលើចំនួនមេធាវីដែលអនុញ្ញាតឲ្យចូលរួមការបណ្តុះបណ្តាល នៅពេលណាមួយនោះ គឺជាកត្តាសំខាន់ដែលបណ្តាលឱ្យខ្វះមេធាវីការពារក្តីនៅកម្ពុជា ជាពិសេសក្នុងតំបន់ក្រៅក្រុងភ្នំពេញ។ IBAHRI ជំរុញឲ្យគណៈមេធាវីអនុវត្តកំណែទម្រង់ដែលនឹងអាចឲ្យគណៈមេធាវីដើរតួនាទីស្ថាបនាក្នុងវិជ្ជាជីវៈផ្នែកច្បាប់នៅកម្ពុជា។

អាស្រ័យហេតុនេះ IBAHRI សូមផ្តល់អនុសាសន៍ឲ្យគណៈមេធាវី ៖

- ប្រកាន់ខ្ជាប់គោលការណ៍តម្លាភាព អភិបាលកិច្ចល្អ និងការទប់ស្កាត់ការអនុវត្តមិនត្រឹមត្រូវពាក់ព័ន្ធនឹងដំណើរការ និងគោលបំណងបំពេញមុខងាររបស់គណៈមេធាវី។
- ធានាថា គណៈមេធាវីមានឯករាជ្យភាពពីរដ្ឋាភិបាលកម្ពុជា។ គណៈមេធាវីគួរផ្តាច់ខ្លួនចេញពីឥទ្ធិពលនយោបាយ និងមិនមានទំនាក់ទំនងនយោបាយ ទាំងផ្លូវការ និងមិនផ្លូវការ ជាមួយគណបក្ស ឬអ្នកនយោបាយណាមួយឡើយ។
- ធានាថា ការគាំទ្រ និងសេវារបស់ខ្លួនត្រូវបានផ្តល់ឲ្យដោយស្មើភាពដល់អ្នកប្រកបវិជ្ជាជីវៈច្បាប់ទាំងអស់នៅកម្ពុជា ដោយមិនមានការរើសអើង។
- ធានាថា មាត្រា ៣២ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានប្រើប្រាស់សម្រាប់តែបេក្ខជនពិសេសដែលមានការអប់រំ និងវិជ្ជាជីវៈ ដែលស័ក្តិសមនឹងផ្តល់ឱ្យពួកគេនូវការអនុគ្រោះពិសេស ដូចមានចែងក្នុងបញ្ញត្តិនៃមាត្រា ៣២។ បេក្ខជនដែលមិនមានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការធ្វើជាមេធាវី ឬបេក្ខជនដែលមិនមានសមត្ថភាពគោរពតាមបទដ្ឋានសីលធម៌វិជ្ជាជីវៈ មិនគួរអនុញ្ញាតឲ្យចូលរួមក្នុងវិជ្ជាជីវៈនេះ ដោយយោងតាមមាត្រា ៣២ ឡើយ។

- បង្កើតការបោះឆ្នោតជាសម្ងាត់សម្រាប់នីតិវិធីបោះឆ្នោតនៅគណៈមេធាវី ដើម្បីកាត់បន្ថយឥទ្ធិពល មិនសមស្របលើអ្នកបោះឆ្នោត
- ធានាថា មិនមានការផ្តល់ ឬទទួលសំណូកដោយគណៈមេធាវី ហើយរាល់ការអនុញ្ញាតឲ្យចូលរួមក្នុងការអប់រំផ្នែកច្បាប់ និងវិជ្ជាជីវៈផ្នែកច្បាប់ត្រូវបានផ្តល់ឲ្យដោយផ្អែកលើគុណសម្បត្តិ និង មិនមែនផ្អែកលើអត្តសញ្ញាណរបស់បេក្ខជន ឬការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុឡើយ។
- បន្តធ្វើការកែលម្អលើការបណ្តុះបណ្តាល និងធនធានផ្នែកច្បាប់ (ក្នុងករណីពាក់ព័ន្ធ ដោយសហការជាមួយគណៈមេធាវីរបស់បណ្តាប្រទេសអាស៊ានផ្សេងទៀត) ដើម្បីបណ្តុះបណ្តាលមេធាវីឱ្យមានជំនាញ និងចំណេះដឹង ក្នុងវិស័យរបស់ខ្លួន និងក្លាយជាសមាជិកមានសមត្ថភាពពេញលេញ នៅក្នុងប្រព័ន្ធតុលាការ។ ការបណ្តុះបណ្តាលផ្នែកច្បាប់គួររួមបញ្ចូលការចូលរួមក្នុងសកម្មភាពមិនគិតថ្លៃ និងការផ្តល់សេវាដល់សហគមន៍ក្រីក្រសំដៅជំរុញក្រមប្រតិបត្តិសីលធម៌។
- ដាក់ឱ្យអនុវត្តនូវប្រព័ន្ធចូលរួមបណ្តុះបណ្តាលវិជ្ជាជីវៈដែលជាកាតព្វកិច្ច សម្រាប់មេធាវីដែលផ្តល់ការអប់រំសមស្របស្តីពីបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ក្រមប្រតិបត្តិ និងក្រមសីលធម៌វិជ្ជាជីវៈ។

## ៦.៥ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់គណបក្សសង្គ្រោះជាតិ

គណៈប្រតិភូ IBAHRI សង្កត់ធ្ងន់លើសារៈសំខាន់នៃការគាំទ្រផ្នែកនយោបាយសម្រាប់ឯករាជ្យភាពនៃអំណាចតុលាការ។ គណបក្សសង្គ្រោះជាតិត្រូវស្វែងរកការដាក់បញ្ចូលឯករាជ្យភាពនៃប្រព័ន្ធតុលាការទៅក្នុងកម្មវិធីនយោបាយរបស់ខ្លួន និងគួរបន្តចោទសួរពីការអនុវត្តរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងប្រព័ន្ធតុលាការ ក្នុងករណីដែលប៉ះពាល់ដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ។ ទោះជាមានគោលនយោបាយទាំងនេះក៏ដោយ គណៈប្រតិភូ IBAHRI មានការព្រួយបារម្ភជាខ្លាំងនៅពេលបានទទួលភស្តុតាងថា គណបក្សសង្គ្រោះជាតិតែងតែចុះកិច្ចព្រមព្រៀងនយោបាយជាមួយគណបក្សប្រជាជន ដែលពាក់ព័ន្ធនឹងសកម្មភាព ដែលប៉ះពាល់ដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ ដូចជាការកំណត់ថ្ងៃដោះលែងអ្នកទោស តាមវិធីក្រៅប្រព័ន្ធតុលាការ។ ការអនុវត្តទាំងនេះបានធ្វើឱ្យបញ្ហាដែលមានស្រាប់កាន់តែធ្ងន់ធ្ងរ ដែលពាក់ព័ន្ធនឹងឥទ្ធិពលរបស់អង្គនីតិប្រតិបត្តិលើប្រព័ន្ធតុលាការ ហើយការអនុវត្តទាំងនេះត្រូវតែបញ្ឈប់។

អាស្រ័យហេតុនេះ IBAHRI សូមផ្តល់អនុសាសន៍ឲ្យគណបក្សសង្គ្រោះជាតិ ៖

- បញ្ឈប់ទម្លាប់ចរចាជាមួយរដ្ឋាភិបាលដើម្បីឲ្យមានការដោះលែងបុគ្គល ឬការលើកចោលនូវការចោទប្រកាន់លើបុគ្គល
- អនុម័តកំណែទម្រង់ប្រព័ន្ធតុលាការ ជាផ្នែកមួយនៃកម្មវិធីនយោបាយសំខាន់ សម្រាប់ការបោះឆ្នោតឆ្នាំ ២០១៨ និង
- ប្រឈមនឹងគណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាល ដើម្បីឱ្យប្រព័ន្ធតុលាការមានឯករាជ្យភាពពិតប្រាកដ។

## ៦.៦ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់សហគមន៍អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា និងប្រទេសផ្សេងទៀត

សហគមន៍អង្គការមិនមែនរដ្ឋាភិបាលដើរតួនាទីសំខាន់ ក្នុងការធានាថា មានការឃ្លាំមើល និងរាយការណ៍ត្រឹមត្រូវពីការគំរាមកំហែងដល់ឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងក្នុងការផ្តល់ការគាំទ្រចាំបាច់ដល់ប្រព័ន្ធតុលាការកម្ពុជា តាមរយៈកម្មទទួលបានយុត្តិធម៌។ សហគមន៍អង្គការមិនមែនរដ្ឋាភិបាលបានប្រកាន់គោលជំហររឹងមាំប្រឆាំងនឹងការវាយប្រហារលើឯករាជ្យភាពនៃអំណាចតុលាការ និងគួរបន្តសកម្មភាពនេះ ដោយចូលរួមជាមួយនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ និងស្ថាប័នអន្តរជាតិផ្សេងទៀត ក្នុងគោលបំណងដើម្បីធានាថា មានការយកចិត្តទុកដាក់គ្រប់គ្រាន់លើបញ្ហានេះ។

ការកាត់បន្ថយថវិកា និងបុគ្គលិកនាពេលថ្មីៗ របស់អង្គការមិនមែនរដ្ឋាភិបាលក្នុងវិស័យយុត្តិធម៌ មានផលប៉ះពាល់អវិជ្ជមានលើប្រព័ន្ធតុលាការកម្ពុជា។ ខណៈដែលជំនួយរបស់អង្គការមិនមែនរដ្ឋាភិបាលលើបញ្ហាប្រព័ន្ធតុលាការជាតិ  មិនមែនជាដំណោះស្រាយរយៈពេលវែងចំពោះបញ្ហាក្នុងប្រព័ន្ធតុលាការកម្ពុជា វិធានការបណ្តោះអាសន្នដ៏សំខាន់នឹងជួយបង្កើនលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់អ្នកដែលមិនសូវមានលទ្ធភាព ជាពិសេសអ្នកដែលរងការចោទប្រកាន់ពីបទឧក្រិដ្ឋនៅក្រៅក្រុងភ្នំពេញ។

អាស្រ័យហេតុនេះ IBAHRI សូមផ្តល់អនុសាសន៍ឲ្យសហគមន៍អង្គការមិនមែនរដ្ឋាភិបាល ៖

- អញ្ជើញអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ទទួលបន្ទុកឯករាជ្យភាពរបស់ចៅក្រម និងមេធាវី ឲ្យរៀបចំបេសកកម្មក្នុងប្រទេសមួយដែលផ្តោតលើបញ្ហាដែលលើកឡើងក្នុងរបាយការណ៍នេះ និងរបាយការណ៍ផ្សេងទៀត

- ចូលរួមកាន់តែខ្លាំងជាមួយនីតិវិធីពិសេសរបស់អង្គការសហប្រជាជាតិ ដើម្បីឆ្លុះបញ្ចាំងកាន់តែច្បាស់ពីបញ្ហាដែលកើតមានក្នុងប្រព័ន្ធតុលាការកម្ពុជា និង
- សហការជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើត និងដំណើរការកម្មវិធីជំនួយផ្លូវច្បាប់សម្រាប់មេធាវីកម្ពុជា ដែលរឹងមាំ និងមានការឃ្លាំមើលពីអន្តរជាតិ ដែលអនុញ្ញាតឲ្យមានតំណាងប្រកបដោយប្រសិទ្ធភាពសម្រាប់ប្រជាជនកម្ពុជាដែលមិនមានលទ្ធភាពជួលមេធាវីការពារក្តី។

## ៦.៧ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់សហគមន៍អន្តរជាតិ

កម្ពុជានៅតែជាប្រទេសមួយ ដែលរងឥទ្ធិពលដ៏ច្រើនលើសលុបពីសហគមន៍អន្តរជាតិ។ IBAHRI ពិចារណាថា តាមរយៈការដាក់សម្ពាធលើរដ្ឋាភិបាលកម្ពុជា និងការជួយដល់រដ្ឋាភិបាលក្នុងការកែលម្អប្រព័ន្ធតុលាការ សហគមន៍អន្តរជាតិអាចដើរតួនាទីវិជ្ជមានក្នុងការគាំទ្រជំរុញប្រព័ន្ធតុលាការកាន់តែល្អប្រសើរ និងមានឯករាជ្យភាព។

អាស្រ័យហេតុនេះ IBAHRI សូមផ្តល់អនុសាសន៍ឲ្យសហគមន៍អន្តរជាតិ ៖

- ជំរុញឲ្យរដ្ឋាភិបាលកម្ពុជាបញ្ឈប់ការដាក់សម្ពាធនយោបាយលើចៅក្រម និងព្រះរាជអាជ្ញាកម្ពុជា ប៉ុន្តែត្រូវដើរតួនាទីស្ថាបនាក្នុងការបង្កើតប្រព័ន្ធតុលាការឯករាជ្យភាពដ៏រឹងមាំ
- សហការជាមួយរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើត និងដំណើរការកម្មវិធីជំនួយផ្លូវច្បាប់សម្រាប់មេធាវីកម្ពុជា ដែលរឹងមាំ និងមានការឃ្លាំមើលពីអន្តរជាតិ ដែលអនុញ្ញាតឱ្យមានការតំណាងប្រកបដោយប្រសិទ្ធភាព សម្រាប់ប្រជាជនកម្ពុជា ដែលមិនមានលទ្ធភាពទទួលបានជំនួយផ្លូវច្បាប់
- បញ្ឈប់ការចូលរួមក្នុងកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលកម្ពុជា ដោយផ្អែកលើការសន្មតថា កម្ពុជាប្រកាន់ខ្ជាប់នីតិរដ្ឋ និង
- បញ្ឈប់ការដាក់លក្ខខណ្ឌឲ្យ អ.វ.ត.ក សម្រេចលទ្ធផលជាក់លាក់ ដែលជាបុរេលក្ខខណ្ឌ ដើម្បីទទួលបានមូលនិធីពីម្ចាស់ជំនួយអន្តរជាតិ។

## ៦.៨ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់គណៈមេធាវីអន្តរជាតិ

ដូចបានកត់សម្គាល់ខាងលើ នាពេលថ្មីៗនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានដើរតួនាទីដែលមិនស្ថាបនា រាំងស្ទះជាញឹកញាប់ និងលម្អៀង ក្នុងការអភិវឌ្ឍវិជ្ជាជីវៈផ្នែកច្បាប់នៅកម្ពុជា។ ក្នុងនាមជាតំណាង IBA អាចប្រើប្រាស់ឥទ្ធិពលលើគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងគួរជំរុញ

គណៈមេធាវី ប្រសិនបើគណៈមេធាវីចង់បន្តធ្វើជាសមាជិករបស់ IBA ដើម្បីធ្វើកំណែទម្រង់សំដៅបង្កើតជាស្ថាប័នមួយដែលអាចផ្តល់ការណែនាំ ការការពារ និងការគ្រប់គ្រងលើវិជ្ជាជីវៈផ្នែកច្បាប់នៅកម្ពុជា។

អាស្រ័យហេតុនេះ IBAHRI សូមផ្តល់អនុសាសន៍ឲ្យ IBA ៖

ពិនិត្យឡើងវិញលើមូលដ្ឋានដែលគណៈមេធាវីកម្ពុជានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានទទួលឲ្យធ្វើជាសមាជិកនៃ IBA។

ជំរុញឲ្យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បញ្ចប់ការអនុវត្តដែលពុករលួយ និងមានលក្ខណៈនយោបាយ ពាក់ព័ន្ធនឹងរបៀបគ្រប់គ្រងវិជ្ជាជីវៈមេធាវី និងការរៀបចំស្ថាប័នផ្ទាល់។ និង

ជំរុញឲ្យគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាដើរតួនាទីរឹងមាំ និងឯករាជ្យ ក្នុងការការពារមេធាវី និងដំណើរការផ្លូវច្បាប់នៅកម្ពុជា ជាពិសេស ប្រឆាំងនឹងសកម្មភាព និងការខកខានពីសំណាក់រដ្ឋាភិបាល។

## ៦.៩ សេចក្តីសន្និដ្ឋាន និងអនុសាសន៍សម្រាប់សហគមន៍ជំនួញអន្តរជាតិ

សហគមន៍វិនិយោគតែងតែពាក់ព័ន្ធ ទោះដោយចេតនា ឬ អចេតនាក្តី ក្នុងបញ្ហារំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរនៅកម្ពុជា។ ជាពិសេស គណៈប្រតិភូមានការព្រួយបារម្ភជាខ្លាំង ចំពោះរបាយការណ៍របស់វិនិយោគិនអន្តរជាតិដែលបដិសេធមិនចូលរួមដោះស្រាយការទាមទារសិទ្ធិដីធ្លីរបស់ប្រជាជនកម្ពុជា ដែលលទ្ធផលនោះ មិនបានជួយឱ្យកម្ពុជាអភិវឌ្ឍដោយវិជ្ជមាននោះទេ ប៉ុន្តែពេលខ្លះការវិនិយោគបានក្លាយជាមធ្យោបាយរំលោភសិទ្ធិមនុស្សទៅវិញ។ ក្រុមហ៊ុន និងអ្នកវិនិយោគអន្តរជាតិ គួរយកចិត្តទុកដាក់នៅពេលមកវិនិយោគនៅកម្ពុជា ដើម្បីធានាថា ការវិនិយោគរបស់ពួកគេ ផ្តល់ផលប៉ះពាល់ជាវិជ្ជមាន និងមានអត្ថន័យលើកម្ពុជា និងមិនផ្តល់លទ្ធភាពដល់ការរំលោភសិទ្ធិមនុស្ស។

អាស្រ័យហេតុនេះ  IBAHRI សូមផ្តល់អនុសាសន៍ឲ្យវិនិយោគិននៅកម្ពុជា ៖

- ធានាថា ពួកគេធ្វើការវាយតម្លៃផលប៉ះពាល់សិទ្ធិមនុស្សយ៉ាងពេញលេញ មុនពេលចុះកិច្ចព្រមព្រៀងវិនិយោគជាមួយរដ្ឋាភិបាលកម្ពុជា។ ជាពិសេស គណៈប្រតិភូសូមជំរុញឲ្យមានការប្រុងប្រយ័ត្ន និងការត្រួតពិនិត្យដោយយកចិត្តទុកដាក់ នៅពេលដែលការវិនិយោគជាប់ពាក់ព័ន្ធនឹងការទិញដីធ្លី។